# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
<u>សាលក្រម</u>
លេខ ១០០ ខ ចុះថ្ងៃទី ០១
ខែ សីហា ឆ្នាំ ២០០៦
<u>សំណុំរឿងរដ្ឋប្បវេណី</u>
លេខ ១៣៨ ចុះថ្ងៃទី ២៧
ខែ មេសា ឆ្នាំ ២០០៦

### តាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

<u>**ចៅក្រមជំនុំជំរះ**</u>

លោក [redacted] ប្រធានតុលាការខេត្ត

<u>**តំណាងអយ្យការ**</u>

លោក[redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

<u>**ក្រឡាបញ្ជីសវនាការ**</u>

លោកស្រី [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ១៣៨ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំលែងលះប្រពន្ធ, ប្តឹងសុំសិទ្ធិគ្រប់គ្រងកូន** ។

រវាងដើមចោទឈ្មោះ **ខ ១ត** ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ របររកស៊ី នៅផ្ទះ ទីលំនៅ។ភូមិថ្នល់ ឃុំស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **ខ ស** (ស) ម្តាយឈ្មោះ **អ សខ** (រ) ប្រពន្ធឈ្មោះ **ឈ ធរ** មានកូន ០១នាក់ ។

និង ចុងចម្លើយឈ្មោះ **ឈ ធរ** ភេទស្រី អាយុ ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ី នៅផ្ទះ ទីលំនៅ។ភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប។ ឪពុកឈ្មោះ **រ សឈ** (រ) ម្តាយឈ្មោះ **ធ សរ** (ស) ប្តីឈ្មោះ **ខ ១ត** មានកូន ០១នាក់ ដោយមានតំណាងលោក **ឈិត ទិនា** ជាមេធាវីការពារក្តី ដែលមានការិយាល័យ ផ្ទះលេខ ៧៦ ផ្លូវលេខ ១០៨ នៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

<u>**ដំណើររឿងមានដូចតទៅ**</u> :

តាមពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដើមចោទឈ្មោះ **ខ ១ត** បានប្តឹងសុំលែងលះចុងចម្លើយឈ្មោះ **ឈ ធរ** ដោយសំអាងហេតុថា បានរៀបការត្រឹមត្រូវតាមច្បាប់ជាមួយចុងចម្លើយតាំងពីឆ្នាំ ១៩៩៩ រហូតមកដល់ពេលនេះមានកូនម្នាក់ឈ្មោះ **១ត រមន** ភេទប្រុស អាយុ ០៦ឆ្នាំ ។ ក្នុងការរស់នៅជាមួយគ្នាកន្លងមកពុំដែលបានចុះសំរុងជាមួយគ្នាទេ ដោយប្រពន្ធរបស់ខ្លួនរករឿងគ្មានហេតុផលពេល

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៦
ដោយពុំមានភាគីណាមួយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា [redacted]

ឈ្លោះគ្នាបន្តិចបន្តួច នាងបានប្រមូលទ្រព្យសម្បត្តិ និង កូនចុះចេញពីផ្ទះរយៈពេលជិតពីរឆ្នាំមកហើយ រហូតដល់ខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ។

## នាពេលសវនាការ

ដើមចោទឈ្មោះ ខ ខ្មត បានឆ្លើយថា ខ្លួនប្តឹងសុំលែងលះចុងចម្លើយ ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នាសោះ ពេលមានរឿងបន្តិចបន្តួចប្រពន្ធប្រមូលទ្រព្យសម្បត្តិ និង កូនចុះចោលខ្លួន បើគិតមកដល់ពេលនេះរយៈពេល ០២ឆ្នាំហើយ ពេលនេះខ្លួនអស់មនោសញ្ចេតនាពីប្រពន្ធហើយ ។ ខ្លួនបានរៀបការត្រឹមត្រូវតាមផ្លូវច្បាប់តាំងពីឆ្នាំ ១៩៩៩ រហូតមកទល់ពេលនេះមានកូនម្នាក់ឈ្មោះ ខ្មត រមន ភេទប្រុស អាយុ ០៦ឆ្នាំខ្លួនសុំសិទ្ធិគ្រប់គ្រង ព្រោះប្រពន្ធរបស់ខ្លួនមានបញ្ហាសុខភាព ។

រីឯទ្រព្យសម្បត្តិរួមពុំមានអ្វីជាក់ពាក់ព័ន្ធគ្នាទេ ហើយបំណុលរួមក៏ពុំមានពាក់ព័ន្ធគ្នាដែរ ។

ចុងចម្លើយឈ្មោះ ឈ ធរ បានឆ្លើយថា ខ្លួនក៏យល់ព្រមលែងលះដើមចោទដែរ ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នាសោះ ហើយលើសពីនេះប្តីបានចុះចោលខ្លួនជាងមួយឆ្នាំ ពេលនេះខ្លួនអស់មនោសញ្ចេតនាពីប្តីហើយ ។ ខ្លួនបានរៀបការត្រឹមត្រូវតាមផ្លូវច្បាប់តាំងពីឆ្នាំ ១៩៩៩ រហូតមកដល់ពេលនេះមានកូនម្នាក់ឈ្មោះ ខ្មត រមន ភេទប្រុស អាយុ ០៦ឆ្នាំ ហើយខ្លួនសុំសិទ្ធិគ្រប់គ្រង ព្រមទាំងសុំទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ៥.០០០ដុល្លា (ប្រាំពាន់ដុល្លាអាមេរិក) ពីប្តីឈ្មោះ ខ ខ្មត និង ថា ពីមុនខ្លួនសុំអោយប្តីជួយផ្តល់ប្រាក់សំរាប់ព្យាបាលជម្ងឺរបស់ខ្លួនចំនួន ៣.០០០ដុល្លា (បីពាន់ដុល្លាអាមេរិក)ដែរ ព្រោះខ្លួនមានជម្ងឺប្រចាំកាយ តែពេលនេះខ្លួនមិនទាមទារប្រាក់ព្យាបាលជម្ងឺចំនួន ៣.០០០ដុល្លា (បីពាន់ដុល្លាអាមេរិក) នេះទៀតទេ ។

ចំពោះទ្រព្យសម្បត្តិរួមមានដី ៣ដីកន្លែង គឺមួយកន្លែងទំហំ ១៥ម គុណ ៣៥ម ស្ថិតនៅភូមិឃុំមិនស្គាល់ ស្រុកពួក ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងខាងត្បូង ខាងកើត មិនស្គាល់ និង ខាងលិចទល់ផ្លូវ. ពីរកន្លែងទៀតទំហំ ០៤ហិកតា (ដីជាប់គ្នា) មានបង្កាន់ដៃទទួលពាក្យ ០២ប្លង់មានទីតាំងស្ថិតនៅភូមិ-ឃុំមិនស្គាល់ស្រុកបន្ទាយស្រី ខេត្តសៀមរាប ហើយ ០៣កន្លែងនេះពុំមានឯកសារអ្វីមកសំអាងឡើយ ត្បិតប្តីយកទៅលក់បានប្រាក់ចាយវាយអស់ហើយ ។ ប៉ុន្តែខ្លួនសុំអោយប្តីចែកចំណែកលក់ដីនេះមកអោយខ្លួនខ្លះ ។ ហើយខ្លួនពុំដឹងថា ទាំងអស់នេះមានទីតាំងច្បាស់លាស់នៅកន្លែងណាទេ ហើយក៏គ្មានឯកសារជាភស្តុតាងឡើយ ។

ចំណែកឯបំណុលរួមពុំមានទេ ។

## មេធាវីការពារក្តីអោយចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា

ចំពោះបញ្ហាកូន ០១នាក់ឈ្មោះ ខ្មត រមន ភេទប្រុស អាយុ ០៦ឆ្នាំនោះ កូនក្តីខ្លួនជាចុងចម្លើយបានខិតខំបីបាច់ ថែរក្សារៀងរហូតមកចាប់តាំងពីពេលបែកលំនៅដ្ឋានពីគ្នានោះមក សូមតុលាការមេត្តាដល់កូនក្តីរបស់ខ្លួនក្នុងសិទ្ធិគ្រប់គ្រងកូន ០១នាក់នេះផង ។ ហើយសូមអោយតុលាការមេត្តាទទួលនូវសំណូមពរទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ ៥.០០០ដុល្លា ( ប្រាំពាន់ដុល្លាអាមេរិក ) ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាប្រភេទរឿងអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលគោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច ដោយមានសភាពធ្ងន់ធ្ងរ ភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបាន

ដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

ទោះបីមានការលែងលះគ្នាក់ដោយភាគីទាំងពីរមិនទុកគ្នាជាសត្រូវ ហើយឪពុកម្តាយត្រូវមានកាតព្វកិច្ចអប់រំ ចិញ្ចឹមកូនតាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្តាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយចុងចម្លើយឆ្លើយដោះសារ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**<u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះបានគ្នាជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទប្តឹងសុំលែងលះចុងចម្លើយ មានមូលហេតុត្រឹមត្រូវតាមច្បាប់ ។

-ចំពោះកូន ០១នាក់ គឺឈ្មោះ ឧត រមន ភេទប្រុស អាយុ ០៦ឆ្នាំ ដើមចោទសុំសិទ្ធិគ្រប់គ្រង ហើយចុងចម្លើយក៏សុំសិទ្ធិគ្រប់គ្រងដែរនោះ តុលាការនឹងពិចារណាដល់បញ្ហានេះ ។ ថា កូនម្នាក់នេះចុងចម្លើយបានថែរក្សាជាប់រហូតមកនោះ គប្បីប្រគល់សិទ្ធិអោយភាគីចុងចម្លើយជាអ្នកគ្រប់គ្រង ។

-ចុងចម្លើយប្តឹងទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ៥.០០០ដុល្លាអាមេរិក ( ប្រាំពាន់ដុល្លាអាមេរិក) ហើយដើមចោទថា គ្មានលទ្ធភាពនោះតុលាការនឹងពិចារណាដល់បញ្ហានេះ ។

-ទ្រព្យសម្បត្តិរួមដើមចោទថា ពុំមានជាប់ពាក់ព័ន្ធគ្នាទេ រីឯចុងចម្លើយថា មានដី ០៣កន្លែង ក៏ប៉ុន្តែពុំមានឯកសារ ឬ ភស្តុតាងណាមួយដែលអាចបញ្ជាក់អំពីអចលនទ្រព្យទាំង ០៣កន្លែងដែលចុងចម្លើយបានលើកឡើងនេះទេ នោះតុលាការពុំអាចយកបញ្ហានេះមកពិចារណាបានឡើយ ។

-បំណុលរួមពុំមានជាប់ពាក់ព័ន្ធគ្នាទេ នោះតុលាការមិនពិចារណាដល់បញ្ហានេះឡើយ ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយហើយ ។

**<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>**

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យលោក ខ ឧសត និង អ្នកស្រី ឈ ធរ លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសលើប្តី ។

៣-សំរេចឱ្យអ្នកស្រី ឈ ធរ ស្ថិតនៅភាពជាមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។

៤-ចំពោះកូន ០១នាក់ គឺឈ្មោះ **ខ្ញត រមេន** ភេទប្រុស អាយុ ០៦ឆ្នាំត្រូវប្រគល់អោយចុងចម្លើយឈ្មោះ **ឈ ធរ** គ្រប់គ្រង ហើយអោយដើមចោទឈ្មោះ **ខ ខ្ញត** បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែ ចំនួន ៣០.០០០៛០០ ( បីម៉ឺនរៀល) ចាប់ពីដំណាច់ខែ សីហា នេះតទៅរហូតដល់កូនមាននីតិភាព ។

មាតាបិតាត្រូវមានសិទ្ធិ និង ករណីកិច្ចអប់រំ ថែរក្សាចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ទុកសិទ្ធិអោយដើមចោទទៅសួរសុខទុក្ខដល់កូនបាន ។

៦-សំរេចបដិសេធបណ្តឹងទាមទារបែងចែកទ្រព្យសម្បត្តិរបស់ចុងចម្លើយឈ្មោះ **ឈ ធរ** ចោល ដោយ បណ្តឹងនេះពុំមានភស្តុតាងបញ្ជាក់អំពីទ្រព្យសម្បត្តិរួមនេះ ។

៧-សំរេចឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្គីង ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ២០០៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛០០ បូករួម ៧.០០០៛០០០ ។ ប្រាក់ នេះបានកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់ទុករួចហើយ ។

៨-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]